ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពត

សាលក្រមរដ្ឋប្បវេណីលេខ ១៩៧ (ឃ)
ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១
សំណុំរឿងរដ្ឋប្បវេណីលេខ ៩៤
ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២១

# គោរនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្ត កំពត

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២១ នៅសាលសវនាការ នៃសាលាដំបូងខេត្តកំពត ។

កាលបរិច្ឆេទប្រកាសសាលក្រម ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ វេលាព្រឹក ។

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពត

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពត

ដើមចោទ ឈ្មោះ [redacted]លេង ភេទ ប្រុស អាយុ ៦២ ឆ្នាំ សញ្ជាតិខ្មែរ ជនជាតិ ខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] ។

ដោយមានលោកស្រីមេធាវី [redacted]ជាអ្នកតំណាងដោយអាណត្តិ ។

ចុងចម្លើយ ឈ្មោះ [redacted]ប៉ែត ភេទ ស្រី អាយុ ៥៤ ឆ្នាំ សញ្ជាតិខ្មែរ ជនជាតិ ខ្មែរ ទីលំនៅបច្ចុប្បន្ន ភូមិ [redacted]។

ដោយមានលោកមេធាវី [redacted]ជាអ្នកតំណាងដោយអាណត្តិ ។

## អង្គហេតុ និងបំណុចវិវាទ៖

១. ការទាមទាររបស់គូភាគី:

ដើមចោទបានប្តឹងទាមទារឱ្យតុលាការសម្រេចចេញសាលក្រមដូចខាងក្រោម:

១.ទទួលស្គាល់កំណត់ហេតុផ្សះផ្សាសំរុះសំរួល ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ រវាងឈ្មោះ [redacted] លេង និងឈ្មោះ [redacted] ប៉ែត ។

២.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ប៉ែត ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើក្បាលដីលេខ: ១៩១១. ក្បាលដីលេខ:៨១០ . ក្បាលដីលេខ: ១៦៨៤ និងក្បាលដីលេខ:៧៥៤ ដោយមូលហេតុនៃការលែងលះតាមការព្រមព្រៀងមកឱ្យឈ្មោះ [redacted] លេង ។

៣.សាលក្រមអាចអនុវត្តជាបណ្តោះអាសន្នបានទាំងមូល ។

៤.ឱ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

២. សេចក្តីថ្លែងការណ៍របស់គូភាគី:



Scanned with CamScanner

២.១. ដើមចោទឈ្មោះ [redacted]លេង ដោយមានលោកស្រីមេធាវី [redacted] ជាអ្នកតំណាងអាណត្តិ បានធ្វើសេចក្តីថ្លែងការណ៍អះអាងថា: ក្នុងនាមខ្លួនជាមេធាវីការពារឱ្យដើមចោទឈ្មោះ [redacted] លេង នៅពេលនេះខ្លួនសុំរក្សាចម្លើយដូចពាក្យបណ្តឹងដែលបានប្តឹងចូលមកតុលាការ កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ហើយចំពោះសំណូមពរ និងការទាមទារ ខ្លួនក៏សូមរក្សាដូចក្នុងពាក្យបណ្តឹងទាំងអស់។ ដូច្នេះសុំឱ្យចុងចម្លើយធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិលើក្បាលដីលេខ:១៩១១, ក្បាលដីលេខ:៨១០, ក្បាលដីលេខ: ១៦៨៤ និងក្បាលដីលេខ: ៧៥៤ ដោយហេតុថាដើមចោទ និងចុងចម្លើយ បានព្រមព្រៀងលែងលះ និងបែងចែកទ្រព្យសម្បត្តិ ដោយមានកំណត់ផ្សះផ្សាចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ មកឱ្យឈ្មោះ [redacted]លេង តាមការព្រមព្រៀង។ ហើយចំពោះកំណត់ហេតុផ្សះផ្សាសំរុះសំរួល ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ រហូតមកដល់ពេលនេះមានរយះពេល ២០ឆ្នាំជាង ហេតុនេះចុងចម្លើយបានផ្លាស់សិទ្ធិ ទើបពេលនេះចុងចម្លើយបដិសេធមិនដឹងថាធ្លើយយ៉ាងមិចទេ តែជាក់ស្តែកចុងចម្លើយបានអនុវត្តកាតព្វកិច្ចដោយទទួល សម្ភារ: អូខេ ចំនួន ១ ម៉ូតូគុបចំនួន ០១គ្រឿង ផ្ទះនៅផ្សារឈូក ០១ខ្នង និងសម្ភារ:ដែលឈ្មោះ [redacted]ប៉ែត ដែលជាចុងចម្លើយ កំពុងលក់ដូរប្រើប្រាស់សព្វថ្ងៃឱ្យទៅឈ្មោះ [redacted] ប៉ែត។ សព្វថ្ងៃឈ្មោះ [redacted] ប៉ែត ក៏កំពុងគ្រប់គ្រងទ្រព្យសម្បត្តិទាំងនោះផងដែរ។ នូវដំណាក់កាលទាញហេតុផល ដែលមានការចូលរួមឈ្មោះ [redacted] ប៉ែត និងអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយបានលើកឡើងត្រឹមការទាមទាររបស់ដើមចោទលើក្បាលដីចំនួន ០៤ កន្លែង ដែលបញ្ជាក់ថាព្រំប្រទល់ច្បាស់លាស់ និងទីតាំងដីស្ថិតនៅភូមិដែលឱ្យដើមចោទដាក់ភស្តុតាង នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១ ដូចការទាមទាររបស់ចុងចម្លើយរួចហើយ។ ចុងចម្លើយមានចេតនាអូសបន្លាយពេលវេលា ក្នុងការកសាងនីតិវិធីប័ណ្ណដីរបស់កូនក្តីខ្លួន ចំនួន ៤កន្លែង ដែលបានមកពីការបែងចែកទ្រព្យសម្បត្តិរួមដែលដើមចោទឈ្មោះ [redacted] លេង គឺទទួលបានដីមូលដ្ឋានពីខាងប្តីគឺដីចំនួន ០៤កន្លែង តាំងពីឆ្នាំ២០០០ នោះគឺទុកឱ្យកូន ០៥នាក់ តែនូវពេលនេះ គាត់មកប្តឹងរំលោភកិច្ចសន្យាសម្រុះសម្រួលនិងបានព្រមព្រៀងទុកឱ្យកូនចៅវិញ។ សូមបញ្ជាក់ថាដីបួនកន្លែងនោះមានដីស្រែបីកន្លែងនិងដីភូមិ០១ បានបញ្ជាក់ឱ្យកូនរួចអស់ហើយ។ ក្នុងនាមខ្លួនជាមេធាវីការពារ និងជាអ្នកតំណាងដោយអាណត្តិខ្លួនសុំសំណូមពរសុំឱ្យតុលាការចេញសាលក្រមដូចជា ១.ទទួលស្គាល់កំណត់ហេតុសំរុះសំរួល ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ រវាងឈ្មោះ [redacted] លេង និងឈ្មោះ [redacted] ប៉ែត។ ២. បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ប៉ែត ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល លើក្បាលដីលេខ ១៩១១ ដែលមានព្រំប្រទល់ខាងជើងទល់នឹងលេខ:១៩០៥ របស់ឈ្មោះ [redacted] ធឿន លេខ:១៩០៦ របស់ឈ្មោះ [redacted] ផាន់នី លេខ:១៩១២ របស់ឈ្មោះ [redacted] គង់ និងលេខ:១៩២០ របស់ឈ្មោះ [redacted] ធឿន ខាងត្បូងទល់នឹងផ្លូវ លេខ១៩០២ របស់ឈ្មោះ [redacted] ធឿន ខាងកើតទល់នឹងលេខ១៩០៦ របស់ឈ្មោះ [redacted] ផាន់នី លេខ ១៩១២ របស់ឈ្មោះ [redacted] គង់ លេខ ១៩២០ របស់ឈ្មោះ [redacted] ធឿន ខាងលិចទល់ លេខ១៩០៥ របស់ឈ្មោះ [redacted] ធឿន និងផ្លូវ ស្ថិតនៅភូមិតូច ឃុំក្រាំងស្នាយ ស្រុកឈូក ខេត្តកំពត។ ក្បាលដីលេខ ៨១០ មានព្រំប្រទល់ខាងជើងទល់នឹងលេខ ៧៣៦ របស់ឈ្មោះ [redacted] សុខលី លេខ ៨១២ របស់ [redacted] ចាន់ជីវ លេខ ៨០១ របស់ឈ្មោះ [redacted] ម៉ារ៉ា ខាងត្បូងដល់នឹងលេខ ៨០២ របស់ឈ្មោះ [redacted] ប៊ុនហៀន ខាងកើតកើតទល់នឹងលេខ ៨០១ របស់ [redacted] ម៉ារ៉ា ខាងលិចទល់ ៧៣៥ របស់ឈ្មោះ [redacted] ធី មានទីតាំងដីស្ថិតនៅភូមិតូច ឃុំក្រាំងស្នាយ ស្រុកឈូក ខេត្តកំពតក្បាលដីទី៣ លេខ

Scanned with CamScanner

ឈ្មោះ [redacted] ធីតា ខាងកើតទល់នឹងលេខ១៦៨៥ របស់ឈ្មោះ [redacted] រ៉ុត និងខាងលិចទល់នឹងផ្លូវ មានទីតាំងស្ថិតនៅភូមិតូច ឃុំក្រាំងស្នាយ ស្រុកឈូក ខេត្តកំពត។ និងក្បាលដីទី៤ លេខ ៧៥៤ មានព្រំប្រទល់ខាងជើង ៧៥២ របស់ឈ្មោះ [redacted] ប៉ាង លេខ ៧៥១ របស់ឈ្មោះ [redacted] ចាន់ចន្ថា ខាងត្បូងទល់ ៧៥១ របស់ឈ្មោះ [redacted] ប៉ាង លេខ៨០៨ របស់ឈ្មោះ [redacted] ថេត ខាងកើតទល់នឹងលេខ ៨០៩ របស់ឈ្មោះ [redacted] ប៉ាង ខាងលិចលេខ ៧៥១ របស់ឈ្មោះ [redacted] ប៉ាង ដែលមានទីតាំងដីនៅភូមិតូច ឃុំក្រាំងស្នាយ ស្រុកឈូក ខេត្តកំពត អោយមកឈ្មោះ [redacted] លេង។ ទីបី សុំអោយសាលក្រមអាចអនុវត្តបាន។ សូមបញ្ជាក់បន្ថែមទៀតថា នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២១ សាលាដំបូងខេត្តកំពត បានកំណត់កាលបរិច្ឆេទនីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ ដោយអ្នកតំណាងឱ្យចុងចម្លើយធ្វើនីតិវិធីត្រៀមឡើងវិញ តែលើចំណុចក្បាលដី តែមិនបានបញ្ជាក់ទីតាំង និងព្រំប្រទល់ ដើម្បីងាយស្រួលឱ្យតុលាការវិនិច្ឆ័យសម្រេចសេចក្តី នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១ ហើយកូនក្តីខ្លួនបានដាក់ភស្តុតាង និងបញ្ជាក់ព្រំប្រទល់ទីតាំងដីរួចហើយ។ ដូចនេះសុំឱ្យតុលាការចេញសាលក្រមតាមការទាមទាររបស់កូនក្តីខ្លួន ។

២.២. ចុងចម្លើយឈ្មោះ [redacted] រ៉ែត ដោយមានលោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ បានថ្លែងការណ៍អះអាងតបថា: ចំណុចទី១ ស្នើសុំឱ្យតុលាការមេត្តាកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមការទាញហេតុផលថ្មី ដើម្បីពិនិត្យនៅលើឯកសារភស្តុតាង ដែលដើមចោទដាក់ចូលមកតុលាការ ព្រោះជាឯកសារនេះមានភាពមិនប្រក្រតី ត្រង់ទំព័រទី១ និងទី២ ដោយហេតុថា ទំព័រទី១ នៃកំណត់ហេតុជាក្រដាស់ដែលមានក្បាលដីពិត។ ចំណែកឯទំព័រទី២ ចុងបញ្ចប់បែរជាចុះហត្ថលេខាដោយមន្ត្រីយុត្តិធម៌ស្រុក និងអភិបាលរងស្រុកទៅវិញ ដោយត្រង់ចំណុច អត់មានបញ្ជាក់ពីស្រុកណាពិតប្រាកដនោះទេ ។ម្យ៉ាងទៀតកូនក្តីខ្លួនបានអះអាងប្រាប់អត្ថន័យ នៃសេចក្តីសម្រេចត្រង់ទំព័រទី១ មិនដូចអ្វីដែលពួកគាត់បានសះជា ជាមួយគ្នានោះទេ ហេតុដូច្នេះខ្លួនសុំស្នើសុំឱ្យតុលាការកោះអញ្ជើញមន្ត្រីដែលធ្វើកំណត់ហេតុនេះមកបំភ្លឺ ព្រមទាំងបង្ហាប់ឱ្យដើមចោទដាក់ឯកសារដើម។ មួយវិញទៀតក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិ ខ្លួនមិនឯកភាពត្រង់ចម្លើយរបស់មេធាវីដើមចោទ ដែលការស្នើសុំមកតុលាការនេះជាការពន្លឿន នីតិវិធីមិនត្រឹមត្រូវឡើយនូវពេលនេះនីតិវិធីត្រៀមទាញហេតុផល ដូចនេះភាគីមានសិទ្ធិលើកឡើងនូវភាពមិនប្រក្រតី ដែលស្ថិតនូវក្នុងឯកសារស័ណ្ឋរឿង ហើយមួយវិញទៀត កូនក្តីខ្លួនជាបុគ្គលមិនចេះអក្សរ។ ដូច្នេះគាត់ចាំអ្វីដែលគាត់បានអះអាង ហើយការដែលភាគីមិនចាំ ដោយហេតុកូនក្តីខ្លួនបានអះអាង ដើមចោទគាត់ទទួលយកនូវសម្ភារៈការ៉ាអូខេ និងទ្រព្យសម្បត្តិមួយចំនួន ដូចដែលមេធាវីដើមចោទលើកឡើងមែន។ ប៉ុន្តែចំពោះដីស្រែនិងដីភូមិមួយគាត់ធ្លាប់ឯកភាពគ្នាទុកចែកឱ្យកូនមិនមែនឱ្យទៅដើមចោទនោះទេ។ ដើមចោទគឺព្រមទទួលយក តុការមួយឈុត គោ ៦ក្បាល និងជ្រូក ៤ក្បាល ដែលភាគីដើមចោទបានទទួលយករួចហើយ ចំណែកឯផ្ទះ ២ខ្នងរោងបាយ១ ដីភូមិ និងដីស្រែចំនួន ៣កន្លែង ពួកគាត់បានព្រមព្រៀងគ្នាតាំងពីឆ្នាំ២០០០ នោះ គឺទុកឱ្យកូនចំនួន ០៥ នាក់ តែនូវពេលនេះដើមចោទគាត់ បានមកប្តឹងរំលោភកិច្ចសន្យាសំរុះសំរួល ដែលព្រមព្រៀងគ្នាទុកដីឱ្យកូនទៅវិញ។ សូមបញ្ជាក់ថា ដីដែលមាននោះមានដីស្រែបីកន្លែងនិងដីភូមិមួយកន្លែង តែបានបញ្ជាក់ឱ្យកូនរួចអស់ហើយ យ៉ាងណាមិញក្នុងនាមខ្លួនជាមេធាវីខ្លួនសុំបដិសេធការទាមទាររបស់ដើមចោទ ដោយហេតុថាការដែលដើមចោទទាមទារទ្រព្យសម្បត្តិនេះ គឺជាការទាមទារទ្រព្យសម្បត្តិដែលបានកំណត់ឱ្យកូនរួចហើយ មួយវិញ

Scanned with CamScanner

រួម លោកអភិបាលរង និងមន្ត្រីយុត្តិធម៌ស្រុក ប៉ុន្តែនៅពេលដែលភាគីដើមចោទ ទៅធ្វើប្លង់កម្មសិទ្ធិជាលក្ខណៈប្រព័ន្ធ ហើយខាងមន្ត្រីជំនាញសុរិយោដីតម្រូវឱ្យមានស្នាមមេដៃរបស់ភាគីចុងចម្លើយ ប៉ុន្តែនៅភាគីដើមចោទបានទៅឱ្យភាគីចុងចម្លើយធ្វើការផ្តិតមេដៃ ភាគីចុងចម្លើយបានបដិសេធមិនព្រមធ្វើការផ្តិតមេដៃនោះទេ ទើបដើមចោទសម្រេចចិត្តដាក់ពាក្យបណ្តឹង ឱ្យតុលាការទទួលស្គាល់ការទាមទារខ្លួន និងបានដាក់ភស្តុតាងបញ្ជាក់ដើម្បីឱ្យតុលាការពិចារណាតាមការទាមទារ ។

៣. តាមការអះអាងតបរបស់ភាគីចុងចម្លើយ ដោយបានសុំធ្វើការបដិសេធ ការទាមទាររបស់ដើមចោទដោយ បញ្ជាក់ពីមូលហេតុថា ការទាមទាររបស់ភាគីដើមចោទ ចំពោះទ្រព្យសម្បត្តិ ដីចំនួន ០៤កន្លែងដែលដើមចោទទាមទារនោះ គឺជាទ្រព្យសម្បត្តិដែលទុកសម្រាប់ឱ្យកូន ម្យ៉ាងវិញទៀតភាគីចុងចម្លើយបានបញ្ជាក់ថា ចំពោះកំណត់ហេតុសំរុះសំរួល ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ មានភាពមិនប្រក្រតី ហើយក្នុងនោះផងដែរមិនបានសរសេរបញ្ជាក់អំពីទ្រព្យសម្បត្តិ ដែលភាគីដើមចោទបានទទួលរួចហើយ។ ភាគីចុងចម្លើយបានធ្វើធ្វើការបញ្ជាក់ថា កំណត់ហេតុសំរុះសំរួលព្រមព្រៀងរបស់ពួកគាត់ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ ការព្រមព្រៀងរបស់ពួកគាត់ គឺដើមចោទត្រូវបានទទួលបានចំណែកដូចជា តុការ មួយកំប្លេរ សំរាប់ប្រកបរបរអាជីវកម្ម និងមានគោ៦ក្បាលនិងជ្រូក ២ក្បាល ដែលទ្រព្យទាំងនេះភាគីដើមចោទទទួលបាន។ ចំណែកឯដីភូមិ និងដីស្រែ ដែលដើមចោទទាមទារនៅពេលនេះក្នុងដំណាក់កាលលែងលះនៅស្រុកឈ្នួក ពួកគាត់បានព្រមព្រៀងគ្នាទុកអោយកូន ។ ត្រង់ចំណុចនេះគប្បីតុលាការ និងពិចារណាតាមភស្តុតាងជាក់ស្តែង ។

៤. ដោយផ្អែកលើការអះអាងរបស់គូភាគីខាងលើ ឃើញថា គូភាគីបានទទួលស្គាល់កំណត់ហេតុផ្សះផ្សាសំរុះសំរួល ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ ប៉ុន្តែដើមចោទបានទាមទារឱ្យតុលាការ បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ប៉ែត ធ្វើនិតិវិធីផ្ទេរកម្មសិទ្ធិទាំងមូល លើក្បាលដីលេខៈ១៩១១ ក្បាលដីលេខៈ៨១០ ក្បាលដីលេខៈ១៦៨៤ និងក្បាលដីលេខៈ៧៥៤ ដោយលើកហេតុផលថា ចុងចម្លើយពុំបានអនុវត្តកាតព្វកិច្ចតាមកំណត់ហេតុផ្សះផ្សាសំរុះសំរួលចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ ដោយមិនបានធ្វើការផ្តិតមេដៃលើដីចំនួន ០៤កន្លែង ដែលជាទ្រព្យសម្បត្តិដែលត្រូវប្រគល់មកឱ្យភាគីដើមចោទ នៅពេលដែលដើមចោទទៅធ្វើការចុះបញ្ជីធ្វើប្លង់កម្មសិទ្ធិជាលក្ខណៈប្រព័ន្ធ។ ការទាមទារ និងការលើកឡើងនេះ ត្រូវបានភាគីចុងចម្លើយបដិសេធមិនទទួលស្គាល់ដោយអះអាងថា ទ្រព្យសម្បត្តិដីចំនួន ០៤កន្លែងដែលភាគីដើមចោទ បានលើកឡើងនោះ គឺចុងចម្លើយបានបញ្ជាក់ថាជាទ្រព្យសម្បត្តិដែលទុកឱ្យកូន មិនមែនប្រគល់ឱ្យភាគីដើមចោទនោះទេ ។

៥. យោងតាមស្ថានភាពការអះអាងរបស់គូភាគី រួមនឹងភស្តុតាង ដូចដែលបានលើកឡើងខាងលើនេះក៏ដូចជាពិចារណាពីកាលៈទេសៈផ្សេងៗទៀត បង្ហាញថា ការលើកឡើងរបស់ដើមចោទមានហេតុផលសមស្របអាចឱ្យតុលាការជឿជាក់បានថា ចុងចម្លើយពិតជាពុំបានអនុវត្តតាមកំណត់ហេតុផ្សះផ្សាសំរុះសំរួល ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ ដែលក្នុងនោះការបែងចែកទ្រព្យសម្បត្តិគូភាគីបានទទួលរៀងៗរួចហើយ ប៉ុន្តែនៅពេលដែលភាគីដើមចោទ សុំឱ្យភាគីចុងចម្លើយធ្វើការផ្តិតមេដៃធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិដីជាលក្ខណៈ ប្រព័ន្ធត្រូវបានភាគីចុងចម្លើយធ្វើការបដិសេធ អនុវត្តកាតព្វកិច្ចរបស់ខ្លួននោះទេ។ ផ្ទុយទៅវិញ ក្រោយពីភាគីចុងចម្លើយបានទទួលដំណឹងពីទាមទារឱ្យធ្វើការផ្តិតមេដៃធ្វើប្លង់លក្ខណៈប្រព័ន្ធ ពីភាគីដើមចោទ ខ្លួនបានបដិសេធមិនព្រម

Scanned with
CamScanner

ដើមចោទទេ។ ហើយតាមស្មារតីនៃការព្រមព្រៀងរបស់ពួកគាត់ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ ការព្រមព្រៀងរបស់ពួកគាត់ គឺដើមចោទត្រូវបានទទួលបានចំណែកដូចជា គុការ មួយកំប្លេរ សំរាប់ប្រកបរបរអាជីវកម្ម និងមានគោ៦ក្បាលនិងជ្រូក ២ក្បាល ដែលទ្រព្យទាំងនេះភាគីដើមចោទទទួលបាន។ ចំណែកឯដីភូមិ និងដីស្រែ ០៣កន្លែង ដែលដើមចោទទាមទារនៅពេលនេះក្នុងដំណាក់កាលលែងលះនៅស្រុកឈ្មោក ពួកគាត់បានព្រមព្រៀងគ្នាទុកអោយកូន។ រីឯចំណែកកំណត់ហេតុសំរុះសំរួល ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ ដែលភាគីដើមចោទដាក់បញ្ចូលភស្តុតាងនៅពេលនេះ ជាភស្តុតាងដែលមានភាពមិនប្រក្រតី ព្រោះថាក្នុងទំព័រទី១ នៃកំណត់ហេតុត្រង់រឹបខាងឆ្វេង នៃក្បាលលិខិតសរសេរថាតុលាការខេត្តក្រុង ហើយរឹបខាងស្តាំទំព័រទី១ ខាងលើចុះលេខសំគាល់ ចំណែកទំព័រទី២ បែរជាមានការចុះហត្ថលេខាដោយមន្ត្រីយុត្តិធម៌ ស្រុកនិងអភិបាលរងស្រុកទៅវិញ។ ត្រង់ចំណុចនេះសបញ្ជាក់ឱ្យឃើញថា កំណត់ហេតុនេះមានភាពមិនប្រក្រតី ដោយប្រការណាមួយលុបបំបាត់នូវចំណុចការព្រមព្រៀងពិតប្រាកដមួយចំនួន រវាងភាគីដូចជាចំណែក ភាគីដើមចោទទទួលរួចហើយតាមការបញ្ជាក់រួមទាំងការព្រមព្រៀងទុកអោយ ។

៣. ចំណុចវិវាទ

ក្នុងរឿងនេះ មានចំណុចវិវាទត្រង់ចំណុច ភាគីចុងចម្លើយបដិសេធមិនព្រមធ្វើការចុះបញ្ជីផ្ទេរ ដី០៤កន្លែង តាមការកំណត់ហេតុផ្សះផ្សាសំរុះសំរួល ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ ទេ? ថាតើកំណត់ហេតុផ្សះផ្សាសំរុះសំរួល ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវដែរឬទេ?

៤. ភស្តុតាង

-កំណត់ហេតុផ្សះផ្សាសំរុះសំរួល ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ រវាងឈ្មោះ [redacted] ប៉ែត និងឈ្មោះ [redacted] លេង ។(ច្បាប់ថតចម្លង)

-ក្បាលដីលេខ:១៩១១។ (ច្បាប់ថតចម្លង)

-ក្បាលដីលេខ:៨១០។ (ច្បាប់ថតចម្លង)

-ក្បាលដីលេខ:១៦៨៤។ (ច្បាប់ថតចម្លង)

-ក្បាលដីលេខ:៧៥៤ ។ (ច្បាប់ថតចម្លង)

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងការពិនិត្យភស្តុតាងនៅក្នុងនីតិវិធី នៃការទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា ៖

១. ពាក្យបណ្តឹងរបស់ឈ្មោះ [redacted] លេង ដែលមានមេធាវី [redacted] តំណាងអោយអាណត្តិ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងត្រឹមត្រូវតាមច្បាប់ ។

២. តាមការអះអាងរបស់ភាគីដើមចោទ បានប្តឹងសុំឱ្យតុលាការទទួលស្គាល់ កំណត់ហេតុផ្សះផ្សាសំរុះសំរួច ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ រវាងឈ្មោះ [redacted] លេង និងឈ្មោះ [redacted] ប៉ែត និង បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ប៉ែត ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើក្បាលដីលេខ: ១៩១១ ក្បាលដីលេខ:៨១០ ក្បាលដីលេខ: ១៦៨៤ និងក្បាលដីលេខ:៧៥៤ ដោយបញ្ជាក់ថា កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ ដើមចោទ និងចុងចម្លើយ បានព្រមព្រៀងគ្នាតាមកំណត់ហេតុផ្សះផ្សាសំរុះសំរួល នៅយុត្តិធម៌ដែលមានសភាពចល

ការលើកឡើងរបស់ភាគីចុងចម្លើយ ដែលបានបញ្ជាក់ និងព្រមព្រៀងតាមកំណត់ហេតុផ្សះផ្សាសំរុះសំរួល គឺផ្ទុយទៅ និងការលើកឡើងទាំងស្រុង (តាមកំណត់ផ្សះផ្សាសំរុះសំរួលចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ បានបញ្ជាក់ពីទ្រព្យសម្បត្តិនៅមូលដ្ឋានខាងប្តីត្រូវទទួលយក ក្នុងនោះមាន ផ្ទះ ផ្ទះបាយ ដីភូមិ ដីនិងស្រែ ដំណាំ ដាំដុះផ្សេងៗទៀត ដែលប្តីគ្រប់គ្រង ) ឃើញថា ការលើកឡើងនេះ គឺពុំសមហេតុផលឡើយដើម្បីឱ្យតុលាការលើកយកពិចារណា ។

៦. យោងតាមស្ថានភាពការអះអាងរបស់គូភាគី រួមនិងភស្តុតាងដូចដែលបានលើកឡើងខាងលើនេះ ក៏ដូចជាពិចារណាពីកាលៈទេសៈផ្សេងៗទៀត បង្ហាញថា ការលើកឡើងរបស់ដើមចោទមានហេតុផលសមស្របអាចឱ្យ តុលាការជឿជាក់បានថាមែនទុកសម្រាប់កូននោះទេ ។

៧. ដើមចោទបានប្តឹងទាមទារឱ្យប្រកាសការអនុវត្តជាបណ្តោះអាសន្ន ត្រង់សេចក្តីសម្រេចទាំងមូល ឃើញថា ការទាមទារនេះ ពុំមានស្ថានភាពណាមួយចាំបាច់តាមផ្លូវច្បាប់ ដែលគប្បីត្រូវតុលាការសម្រេចនោះឡើយ ។

៨. យោងតាមការលើកឡើងក្នុងសំអាងហេតុខាងលើទាំងអស់នេះ បានបង្ហាញឱ្យឃើញថា ការទាមទារក្នុងបណ្តឹងរបស់ដើមចោទ មានមូលដ្ឋានគ្រប់គ្រាន់ ភស្តុតាងច្បាស់លាស់ ហេតុផលសមស្រប និងត្រឹមត្រូវតាមច្បាប់ ហេតុដូច្នេះ គប្បីតុលាការសម្រេចនូវការទាមទារនេះ ។

៩. យោងតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី ហេតុដូចនេះ គប្បីតុលាការពិចារណា និងសម្រេចអំពីបន្ទុកប្រាក់ប្រដាប់ក្តីនេះទៅតាមការកំណត់របស់ច្បាប់។

## សេចក្តីសម្រេចបញ្ចប់

១/. ទទួលស្គាល់កំណត់ហេតុផ្សះផ្សារសំរុះសំរួល ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ រវាងឈ្មោះ [redacted] លេង និងឈ្មោះ [redacted] ប៉ែត ត្រឹមត្រូវតាមច្បាប់ ។

២/. បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ប៉ែត ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើក្បាលដីលេខ: ១៩១១. ក្បាលដីលេខ:៨១០. ក្បាលដីលេខ: ១៦៨៤ និងក្បាលដីលេខ:៧៥៤ ដោយមូលហេតុនៃការលែងលះតាមការព្រមព្រៀងមកឱ្យឈ្មោះ [redacted] លេង ។

៣/. ច្រានចោលការទាមទារឱ្យប្រកាសការអនុវត្តជាបណ្តោះអាសន្នទាំងមូល របស់ដើមចោទ ។

ចៅក្រម

ហត្ថលេខា និងត្រា [redacted]

---

បានឃើញ

ចៅក្រម

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ៨កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

កំពត,ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១

ក្រឡាបញ្ជី

Scanned with CamScanner